Australian Embassy
Cambodia

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

*ថ្ងៃព្រហស្បតិ៍ ៧កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥*

# សេចក្តីប្រកាសព័ត៌មានរួម
# ស្តីពីវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន អបអរសាទរខួប ២៥ឆ្នាំ
# នៃកិច្ចសន្ទនា ភាពជាដៃគូ និងកំណែទម្រង់

ថ្ងៃនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(ក.អ.ក.) បានរៀបចំសិក្ខាសាលាកម្រិតខ្ពស់មួយ ដោយមានការគាំទ្រពីប្រទេសអូស្ត្រាលី ដើម្បីផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) លើកទី១៩ ប្រចាំឆមាសទី១ ឆ្នាំ២០២៥ និងចូលរួមអបអរសាទរខួប ២៥ឆ្នាំ នៃការបង្កើតវេទិកាកម្រិតខ្ពស់បំផុតរបស់កម្ពុជា សម្រាប់កិច្ចសន្ទនារវាងរាជរដ្ឋាភិបាល និងផ្នែកឯកជន។

វេទិកាG-PSF ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៩ ក្រោមគំនិតផ្តួចផ្តើមប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភានៃ**ព្រះរាជាណាចក្រកម្ពុជា** ដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជននិងការស្តារសេដ្ឋកិច្ចឡើងវិញ ក៏ដូចជាការផ្តល់លទ្ធភាពឱ្យវិស័យឯកជនក្លាយជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ច។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក.អ.ក.** និងជាប្រធានគណៈកម្មាធិការសម្របសម្រួលការងារសម្រាប់យន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (**គ.ស.រ.ជ.**) និងស្របពេលដែលកម្ពុជាទទួលបានកំណត់ត្រាថ្មីមួយនៃការអនុម័តគម្រោងវិនិយោគ ដែលក្នុងរយៈពេលជិត១១ខែនៃឆ្នាំ២០២៥ បានអនុម័តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ.) ជិត ៦០០គម្រោង ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ៩,៤ប៊ីលានដុល្លារអាម៉េរិក។ តួលេខនេះ គឺលើសកំណត់ត្រាដែលសម្រេចបាននៅក្នុងឆ្នាំ២០២៤ ដែលក្នុងរយៈពេល១ឆ្នាំពេញ បានអនុម័ត គ.ល.គ. ចំនួន ៤១៤គម្រោង។

របាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ ប្រចាំឆមាសទី១ ឆ្នាំ២០២៥ បានទទួលការឯកភាពពីកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ កន្លងទៅ។ របាយការណ៍នេះ បានរៀបរាប់លម្អិតអំពីវឌ្ឍនភាពនៅតាមវិស័យកំណែទម្រង់អាទិភាព រួមមាន ពាណិជ្ជកម្ម ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធ ពន្ធដារ ពន្ធគយ កសិកម្ម និងការធ្វើសាមញ្ញកម្មបទប្បញ្ញត្តិ។ របាយការណ៍នេះ ក៏រំលេចផងដែរនូវ វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់ដែលបានដាក់ចេញក្នុងវេទិកា G-PSF លើកទី១៩ របស់បណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមការងារតាមវិស័យ ដោយវិធានការដែលសម្រេចពេញលេញមានចំនួន ៩៣% និងវិធានការនៅសេសសល់

ចំនួន ៧%ទៀត គឺកំពុងបន្តអនុវត្ត ដែលបង្ហាញថាការអនុវត្តវិធានការកំពុងដំណើរការយ៉ាងរលូន ឈានទៅរកវេទិកា G-PSF លើកទី២០ ដែលរំពឹងថានឹងរៀបចំឡើងនៅក្នុងឆ្នាំ២០២៦ ខាងមុខនេះ។ របាយការណ៍វឌ្ឍនភាពក៏បានរំលេចនូវវឌ្ឍនភាពនៃការដោះស្រាយបញ្ហា ដែលបានលើកឡើងនៅតាមក្រុមការងារតាមវិស័យទាំង១៦ ផងដែរ។

**ឯកឧត្តម ស៊ុន ចាន់ថុល** បានថ្លែងថា «ក្នុងពេលដែលយើងប្រារព្ធពិធីអបអរសាទរខួប ២៥ឆ្នាំ នៃការបង្កើតយន្តការ G-PSF នាពេលនេះ យន្តការនេះគឺកាន់តែមានសារៈសំខាន់ជាងពេលណាៗទាំងអស់។ ក្នុងបរិបទនៃបញ្ហាប្រឈមថ្មីៗក្នុងតំបន់ រួមមានបម្រែបម្រួលនៃបរិបទពាណិជ្ជកម្មសកល យន្តការនេះនឹងជួយពង្រឹងសមត្ថភាពស្ថាប័ន និងគាំទ្រវិស័យឯកជន ក្នុងការសម្រេចបាននូវសក្តានុពលជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចកម្ពុជា។ យើងនឹងបន្តអភិវឌ្ឍយន្តការ G-PSF និងធានាឱ្យបាននូវលទ្ធផលប្រកបដោយផ្លែផ្កា នៃកិច្ចសន្ទនារបស់ក្រុមការងារតាមវិស័យនៃវេទិកា G-PSF »។

**ឯកឧត្តម ដេរិក ឃើប ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា** បានថ្លែងថា «អូស្ត្រាលីគាំទ្រដល់ការរៀបចំគោលនយោបាយដែលពឹងផ្អែកលើមូលដ្ឋានភស្តុតាងរឹងមាំ និងកិច្ចសន្ទនាដែលប្រកបដោយបរិយាបន្ន។ យើងសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ ក.អ.ក និងសភាពាណិជ្ជកម្មកម្ពុជា ក្នុងការចូលរួមយ៉ាងសកម្ម និងមានប្រសិទ្ធភាពនៅក្នុងវេទិកាដ៏សំខាន់មួយនេះ ដែលជួយសម្រួលដល់កិច្ចសន្ទនាគោលនយោបាយ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា»។

សភាពាណិជ្ជកម្មកម្ពុជា ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលផ្នែកឯកជននៃវេទិកា G-PSF ដោយបានបង្ហាញនូវទស្សនៈនិងគោលគំនិតរបស់ពួកគេ និងផ្តល់នូវអនុសាសន៍រួមដល់រាជរដ្ឋាភិបាលកម្ពុជា។ ការអនុញ្ញាតឱ្យវិស័យឯកជនចូលរួមចំណែកក្នុងសេដ្ឋកិច្ច គឺជាគន្លឹះសំខាន់ក្នុងការសម្រេចបាននូវលទ្ធផលផ្នែកសេដ្ឋកិច្ច និងការអភិវឌ្ឍ។

ប្រទេសអូស្ត្រាលី បានចាប់ផ្តើមផ្តល់ការគាំទ្រដល់យន្តការ G-PSF ក្នុងឆ្នាំ២០០២ ដោយបានផ្តល់ជំនួយគាំទ្រស្របគ្នាជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដល់ការកសាងលេខាធិការដ្ឋាន G-PSF ។ ប្រទេសអូស្ត្រាលីបានបន្តភាពជាដៃគូនេះឡើងវិញនៅក្នុងឆ្នាំ២០២៣ តាមរយៈកម្មវិធីភាពជាដៃគូកម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED)។ ជំនួយគាំទ្រនេះ ត្រូវបានផ្តល់ជូន ក.អ.ក., សភា-ពាណិជ្ជកម្មកម្ពុជា និងក្រុមការងារតាមវិស័យទាំង១៦ នៃវេទិកា G-PSF និងផ្តោតសំខាន់លើការពង្រឹងសមត្ថភាពរបស់តួអង្គពាក់ព័ន្ធនៃយន្តការ G-PSF សំដៅជំរុញការអនុវត្តកំណែទម្រង់ឱ្យបានទាន់ពេលវេលា និងប្រកបដោយគណនេយ្យភាព។

សិក្ខាសាលានេះ ក៏មានការចូលរួមពីតំណាងក្រុមការងាររាជរដ្ឋាភិបាលនិងផ្នែកឯកជននៃវេទិកា G-PSF ទាំង ១៦ សភាពាណិជ្ជកម្មកម្ពុជា ស្ថានទូត សភាពាណិជ្ជកម្មអន្តរជាតិ សមាគមធុរកិច្ច និងដៃគូអភិវឌ្ឍន៍នានា៕

**សម្រាប់សាកសួរព័ត៌មានបន្ថែម៖** Media.Cambodia@dfat.gov.au